**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណាវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា



www.pheakdeylaw.com

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល (Kompong Chheuteal Institute of Technology ) សរសេរកាត់ជាភាសាខ្មែរ **វ.ប.ក.ឈ.** និងជាភាសាអង់គ្លេស K.C.I.T ។

**មាត្រា២.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា។

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល មានទីតាំងស្ថិតនៅភូមិសំបូរ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។

**មាត្រា៣.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល មានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាលអ្នកជំនាញបច្ចេកទេសកម្រិតបឋម អ្នកជំនាញបច្ចេកទេសកម្រិតមធ្យម និងអ្នកបច្ចេកទេសកម្រិតឧត្តម
- ស្រាវជ្រាវ និងធ្វើសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិ និងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា
- លើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេសដល់គ្រូបង្រៀន និងគ្រូបច្ចេកទេស
- អភិវឌ្ឍកម្មវិធីសិក្សាឲ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារសមត្ថភាព និងកម្រិតគុណវុឌ្ឍិជាតិ ជ្រើសរើសសិស្ស និស្សិតឲ្យចូលរៀន ស្របតាមគោលការណ៍កំណត់
- កសាងផែនការអភិវឌ្ឍន៍រយៈពេលខ្លី មធ្យម និងវែង
- គ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក គ្រូបង្រៀន កម្មករ និស្សិត និងទ្រព្យសម្បត្តិ។

**មាត្រា៤.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល បណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិតទី១ កម្រិតទី២ កម្រិតទី៣ (៩+១+១+១) សញ្ញាបត្របរិញ្ញាបត្ររង(១២+២ ឬ ៩+៣+២) សញ្ញាបត្របរិញ្ញាបត្រ (២+២) លើមុខជំនាញ អេឡិចត្រូនិច ទូរគមនាគមន៍ អនុភាពអគ្គិសនី វិទ្យាសាស្ត្រសត្វ វិទ្យាសាស្ត្រដំណាំ កុំព្យូទ័រ ពាណិជ្ជកម្ម គ្រប់គ្រងទេសចរណ៍ និងសណ្ឋាគារ គ្រូអប់រំបំណិនជីវិត ជំនាញអេឡិចត្រូនិច-អគ្គិសនី អេឡិចត្រូនិច-កុំព្យូទ័រ ក្សេត្រសាស្ត្រ-បសុវប្បកម្ម និងគ្រូបច្ចេកទេសកម្រិតឧត្តម (បរិញ្ញាបត្រ.១)លើជំនាញ អេឡិចត្រូនិច អគ្គិសនី បសុវប្បកម្ម ក្សេត្រសាស្ត្រ កុំព្យូទ័រ គ្រប់គ្រងទេសចរណ៍ និងសណ្ឋាគារ។

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល អាចបើកមុខជំនាញថ្មី ឬ កម្រិតបណ្តុះបណ្តាលបន្តដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល មាន៧ ដេប៉ាតឺម៉ង់ ៖

- ដេប៉ាតឺម៉ង់អគ្គិសនី



www.pheakdeylaw.com

- ដេប៉ាតឺម៉ង់អេឡិចត្រូនិច
- ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកំព្យូទ័រ
- ដេប៉ាតឺម៉ង់បសុវប្បកម្ម
- ដេប៉ាតឺម៉ង់កសិក្រសាស្ត្រ
- ដេប៉ាតឺម៉ង់ទេសចរណ៍ និងសណ្ឋាគារ
- ដេប៉ាតឺម៉ង់បណ្តុះបណ្តាលគ្រូបង្រៀន ផ្នែកអប់រំបំណិនជីវិត។

ទៅអនាគត វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាលនឹងអាចបើកមហាវិទ្យាល័យ ដេប៉ាតឺម៉ង់ កម្រិត ឬប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការ និងការងារពាក់ព័ន្ធផ្សេងៗទៀតរបស់វិទ្យាស្ថាន។

**មាត្រា៧.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ត្រូវដឹកនាំដោយនាយកមួយរូប ដែលមានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករងមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៨.-**

សិស្ស និស្សិតដែលបានរៀនចប់តាមកម្មវិធីសិក្សារបស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល និងទទួលបានជោគជ័យក្នុងការបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវផ្តល់ឲ្យដោយវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ផ្អែកលើបញ្ជីឈ្មោះសិស្ស និស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៩.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល មានប្រភពធនធានដូចខាងក្រោម៖

- ថវិកាជាតិដែលជាឧបសម្ព័ន្ធក្នុងកញ្ចប់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា
- ថវិកាដែលស្ថិតក្នុងកញ្ចប់មូលនិធិរបស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល
- ការបង់ថ្លៃបណ្តុះបណ្តាល
- ប្រភពផ្សេងៗទៀត។

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀតពីប្រភពខាងក្នុង ឬ ក្រៅប្រទេសសម្រាប់បម្រើសេចក្តីត្រូវការរបស់ខ្លួន។



www.pheakdeylaw.com

**មាត្រា១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារកាលប្បវត្តិ



www.pheakdeylaw.com